# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ឡាច មៀន K09319
## សម្ភាសន៍ជាមួយ ឡាច មៀន អាយុ៤៤ឆ្នាំ
## ជាអ្នកសួរចម្លើយនៅទួលស្លែង
## ភូមិស្ពានដែក ឃុំធ្លកវៀន ស្រុកសាមគ្គីមានជ័យ ខេត្តកំពង់ឆ្នាំង
## ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០២
## សម្ភាសន៍ដោយៈ អ៊ីសា ឧស្មាន និង វ៉ាន់ថាន់ ពៅដារ៉ា
## សរុបៈ ២៦ទំព័រ

ឧស្មានៈ បង, ខ្ញុំសុំស្គាល់ឈ្មោះបងផង?

មៀនៈ ខ្ញុំឈ្មោះ ឡាច មៀន ។

ឧស្មានៈ បងអាយុប៉ុន្មាន?

មៀនៈ អាយុ៤៤ ។

ឧស្មានៈ នៅភូមិនេះ គេហៅភូមិអីបង?

មៀនៈ ស្ពានដែក ។

ឧស្មានៈ ឃុំ?

មៀនៈ ធ្លកវៀន ។

ឧស្មានៈ ស្រុក?

មៀនៈ សាមគ្គីមានជ័យ ។

ឧស្មានៈ ស្រុកកំណើតបង?

មៀនៈ នៅភូមិហ្នឹងដែរ ។

ឧស្មានៈ ឪពុកបងឈ្មោះអី?

មៀនៈ ឈ្មោះ ឡាច ឡុង ។

ឧស្មានៈ គាត់នៅរស់ទេ?

មៀនៈ ស្លាប់ ។

ខស្នានៈ ស្លាប់ពេលណា?

មៀនៈ ស្លាប់ឆ្នាំ៨៤ ។

ខស្នានៈ ចុះម្តាយឈ្មោះអីបង?

មៀនៈ ឈ្មោះ ម៉ម សុន ។

ខស្នានៈ គាត់នៅរស់ទេ?

មៀនៈ បាទ, នេះគាត់ ។

ខស្នានៈ លោកយាយអាយុប៉ុន្មានហើយ?

ម្តាយមៀនៈ ៨៣ហើយ ។

ខស្នានៈ ប្រពន្ធបងឈ្មោះអីបង?

មៀនៈ ឈ្មោះ ឆូ ខុម ។

ខស្នានៈ អាយុប៉ុន្មាន?

ប្រពន្ធមៀនៈ ៣៣

ខស្នានៈ បងរៀបការជាមួយប្រពន្ធបងនៅឆ្នាំណា?

មៀនៈ ឆ្នាំ៧៩ ។

ខស្នានៈ ហើយសព្វថ្ងៃមានកូនប៉ុន្មាននាក់ហើយ?

មៀនៈ កូន៧នាក់ ។

ខស្នានៈ កូនធំជាងគេហ្នឹង កូនទី១អាយុប៉ុន្មាន?

មៀនៈ .....(២៣) .... ។

ខស្នានៈ បង ខ្ញុំសុំបងរៀបរាប់ប្រវត្តិបងខ្លះ ប្រវត្តិតាំងតូចម៉ោដូចជាការរៀនសូត្ររបស់បង រហូតដែលបងចាកចេញពីផ្ទះទៅធ្វើអីនៅកន្លែងណា ហើយបើសិនជាចាំឆ្នាំហ្នឹង សូមបង ជួយប្រាប់ផង ព្រោះឆ្នាំទីកន្លែងអីណឹង ខ្ញុំចង់បានហើយវាមានសារៈសំខាន់, អីចឹងបង សូមប្រាប់មើល តើបងបានធ្វើអីខ្លះពីតូចរហូតម៉ោ?

មៀនៈ តូចម៉ោ ១២(ឆ្នាំ) នៅរៀន,

ខស្នានៈ និយាយតទៀតបង? រៀននៅសាលាណា?

មៀនៈ សាលាស្ពានដែក ពីដើមគេហៅសាលាវត្តឈូក ហើយឥឡូវគេហៅសាលាស្ពានដែក ។

ឧស្មានៈ រៀនបានថ្នាក់ណាបង?

មៀនៈ ទី១០, ទី១០ពីដើម ទី១០ចាស់ មិនមែន១០ឥឡូវទេ ។

សុជាៈ ក្នុងឆ្នាំណាដែរបង?

មៀនៈ ឆ្នាំ៦៨...៧០...៧១.........បួស ។

ដារ៉ាៈ បួសនៅវត្តណាបង?

មៀនៈ បួសនៅវត្តឈូកដដែល ។

ដារ៉ាៈ បួសប្រហែលប៉ុន្មានឆ្នាំ?

មៀនៈ បួសតាំងពី៧១រហូតដល់៧៤(ដើម៧៤) ។

ឧស្មានៈ បន្ទាប់ម៉ោទៀត?

មៀនៈ បន្ទាប់ម៉ោទៀត ខ្ញុំសឹក សឹកពីបួសម៉ោ... ។

ឧស្មានៈ សឹកទៅណាទៀត?

មៀនៈ សឹកពីបួសម៉ោខ្ញុំធ្វើឈ្លប ធ្វើគេហៅឈ្លបពីដើមឈ្លបឃុំ, ឈ្លបខ្មែរក្រហមពីដើម ។

ដារ៉ាៈ ឈ្លបឃុំនៅឃុំណា?

មៀនៈ ឃុំធ្លកវៀន ។

ដារ៉ាៈ ក្នុងឆ្នាំណាបងធ្វើឈ្លបឃុំ?

មៀនៈ ឆ្នាំ៧៤ដដែល, ខ្ញុំសឹកពីឆ្នាំ៧៤ ។ សឹកម៉ោបានប្រហែលម៉ាអាទិត្យ គេហៅម៉ោធ្វើឈ្លបបណ្តោយ ។

ឧស្មានៈ ចុះសឹក ហេតុអីបានបងសឹក?

មៀនៈ គេមិនផ្សឹកទេ តែវាពិបាកពេកនៅវត្តនោះ គ្មានបានបួសបានរៀនទេ គ្រាន់មានឈ្មោះបួសទេ តែល្ងាចឡើងវែកដីទំនប់ ព្រលឹមឡើងវែកដីទំនប់ គ្មានបានរៀនធម៌ រៀនសូត្រអីទេ ទៅវត្តជ័យនោះ ។

ឧស្មានៈ វត្តអី?

មៀនៈ វត្តជ័យ ។ ជម្លៀសពីវត្តឈូកនេះទៅ ទៅនៅវត្តជ័យគេឲ្យលើកទំនប់ លោកលើកទំនប់ ។

ឧស្មានៈ នៅជាលោកសង្ឃ?

មៀនៈ ជាសង្ឃណុងណាំ, វាពិបាកពេកសឹកម៉ោ ។ សឹកម៉ោបានប្រហែលជាម៉ាអាទិត្យ គេហៅម៉ោ ឲ្យធ្វើឈ្លប, ឈ្លបឃុំ ។

ដារ៉ាៈ កិច្ចការឈ្លបឃុំ បងធ្វើអីខ្លះ

មៀនៈ ឈ្លបឃុំហ្នឹងគេឲ្យទៅឆ្មក់ទាហាន ស៊ើបការណ៍ទាហាននៅសាលាលេខ៥ លង្វែកអី ។

ដារ៉ាៈ មាននរណាជាប្រធាន?

មៀនៈ ប្រធានណឹង សាន់ ។

ដារ៉ាៈ ហើយបន្ទាប់មកទៀត?

មៀនៈ សាន់ ហ្នឹងប្រធានឈ្លប តែ តានៅ ហ្នឹងគាត់គណៈឃុំ ។

ដារ៉ាៈ តានៅ?

មៀនៈ ហ្នឹងហើយតានៅ ។

ខស្នានៈ ចុះមូលហេតុអីបានបងចូលឈ្លប?

មៀនៈ គេហៅម៉ោតែម្តង, មិនមែនចូលខ្លួនឯងឯណា គេហៅម៉ោ ។

ខស្នានៈ ពេលសឹកហើយ ម៉ោនៅជាមួយឪពុកម្តាយ?

មៀនៈ ម៉ោផ្ទះបាន៧ថ្ងៃ គេម៉ោហៅធ្វើសំបុត្រហៅឲ្យម៉ោចូលឈ្លប ។

ដារ៉ាៈ ខាងណាធ្វើសំបុត្រ?

មៀនៈ ខាងឃុំហ្នឹងហើយ ខាងតាសាន់ហ្នឹងហើយ ខាងឈ្លបឃុំហ្នឹងហើយ ។

ខស្នានៈ ហើយពេលហ្នឹងទឹកចិត្តបងយ៉ាងម៉េច ចង់ធ្វើឈ្លបនឹងគេនឹងឯង?

មៀនៈ ការចង់ អត់ចង់ទេ តែគេហៅហើយបើមិនទៅ កាលណុងសម័យនោះវាពិបាកដែរ ។ ..អត់ទៅការចាត់តាំងរបស់គេក្រិតក្រម បើចាត់តាំងឲ្យទៅណាត្រូវតែទៅ ។ អត់ហ៊ានប្រកែកទេ តែម៉ាត់អត់ហ៊ានប្រកែកនឹងគេដែរ ។

ដារ៉ាៈ បន្ទាប់ពីធ្វើឈ្លបឃុំហើយ ធ្វើអីទៀត?

មៀនៈ ធ្វើឈ្លបឃុំបានប្រហែលជាមួយខែពីរខែមិនយូរប៉ុន្មានទេ បានគេបញ្ជូនមកឲ្យនៅទ័ពស្រុក

ដារ៉ាៈ ស្រុកអីគេ?

មៀនៈ ស្រុកពីដើមគេហៅស្រុកកំពង់ត្រឡាចលើ ស្រុក១២ ។

ខស្នានៈ អីចឹងនៅក្នុងឆ្នាំណាដែរ?

មៀនៈ ៧៨ដដែល ចុង៧៨ ។

ដារ៉ាៈ អាចចាំខែទេបង?

មៀនៈ អត់ចាំទេ ។

ដារ៉ាៈ អាចដាខែខ្មែរ ខែច្រូត ឬខែអី?

មៀនៈ ខែកាលណឹងគេបញ្ជូនឲ្យទៅនៅស្រុកខែធ្លាក់ភ្លៀងម្តង, ខែពិសាខ ។

ដារ៉ាៈ បញ្ជូនទៅស្រុកកំពង់ត្រឡាចលើ គេធ្វើអីពូ?

មៀនៈ ទាហាន, ទ័ពខ្មែរក្រហម ។

ដារ៉ាៈ ដើរច្បាំងសមរភូមិណាខ្លះ?

មៀនៈ គេឲ្យទៅនៅខ្សែត្រៀមនៅលង្វែក, រោងចក្រ....

សុជាៈ កាលណឹងបងមានចាំថា ប្រធានបងឈ្មោះអីដែរបង?

មៀនៈ ប្រធានទ័ពស្រុកឈ្មោះ យឺន, កងវរយខ្ញុំណ៎ា ។

ខស្មានៈ ត្រកូលអី យឺន?

មៀនៈ អត់ស្គាល់ត្រកូលទេ ស្គាល់តែតាយឺន ។

ខស្មានៈ ស្រុកកំណើតនៅឯណាដែរ?

មៀនៈ មិនដឹងនៅឯណាដែរទេ ។

ដារ៉ាៈ រាងគាត់យ៉ាងម៉េចតាយឺន?

មៀនៈ រាងប្រហែលតែគាត់ដែរហ្នឹង(មៀនចង្អុលដាក់ខស្មាន) តែរៀងខ្មៅជាងហ្នឹងមិនសទេ ។

ដារ៉ាៈ ហើយបន្ទាប់ពី យឺន មានអ្នកណាទៀត?

មៀនៈ ជី និត អាហ្នឹងកងវរយ ។ ដល់ពេលកងហានេះ ចេវទេ, ជួបវារាល់ថ្ងៃ ។

ខស្មានៈ ឈ្មោះអី?

មៀនៈ ចេវ, ធ្លកវៀនយើងនេះ ។

ខស្មានៈ នៅភូមិអី?

មៀនៈ នៅភូមិធ្លកវៀននេះដែរ, មេកងហាខ្ញុំហើយហ្នឹង ។

ដារ៉ាៈ នៅការងារទ័ពហ្នឹងនៅស្រុក១២ ដល់ខែណាឆ្នាំណាទៅ?

មៀនៈ នៅរហូតទល់ដល់គេវ៉ៃបែកភ្នំពេញ ។

ដារ៉ាៈ ដល់ពេលបែកភ្នំពេញហើយ បងទៅណាទៀត?

មៀនៈ បែកភ្នំពេញហើយបានប្រហែលជា៣-៤ខែហើយយូរដែរ, ស្អួនហ្នឹងរួចបានបែកភ្នំពេញ, បែកខែ៤ណា៎, ខែ៤ស្អួនទៅហ្នឹងរួចបានបញ្ជូនខ្ញុំទៅភ្នំពេញ ។

ដារ៉ាៈ បញ្ជូនទៅភ្នំពេញហើយនៅម្តុំណាអីម្តុំណែ?

មៀនៈ ដំបូងគេនៅចិញ្ចឹមជ្រូក, នៅបឹងទំពុន ។

ខស្មានៈ ឆ្នាំណាកាលទៅនោះ?

មៀនៈ ឆ្នាំ៧៥ ។

ខស្មានៈ ខែណា?

មៀនៈ ប្រហែលជាខែ៨ ។

ខស្មានៈ ហើយទ័ពស្រុកដែលគេយកទៅភ្នំពេញ គេយកទៅទាំងអស់ ឬមានការជ្រើសរើស?

មៀនៈ ជ្រើសរើស ។

ខស្មានៈ ជ្រើសរើសយ៉ាងម៉េច?

មៀនៈ ម៉ាស្រុកហ្នឹងច្រើនដែរ, មិនដឹងជ្រើសរើសយ៉ាងម៉េចទេ តែគេចាត់តាំងឲ្យទៅ ។

ខស្មានៈ គេយកប៉ុន្មាននាក់ដែរ?

មៀនៈ ម៉ាស្រុកច្រើនណាស់, ម៉ាខេត្តមិនមែនម៉ាស្រុកទេ, ទៅ២ឡានណោះ ឡានសេម៉ាសេ ។ គេរើសតាមមួយកងពីរៗអីចឹងទៅណា៎ ។

ដារ៉ាៈ បងមានស្គាល់មិត្តភក្តិអីទៅជាមួយទេម៉ាជំនាន់នោះ?

មៀនៈ ស្គាល់ដែរមិត្តភក្តិដែលទៅជាមួយ ស្គាល់ច្រើនតែឥឡូវវាបែកគ្នា បាត់អស់ខ្លះស្លាប់ខ្លះអី ។

ដារ៉ាៈ មានចាំឈ្មោះខ្លះទេ?

មៀនៈ ចាំ ។

ដារ៉ាៈ ឈ្មោះអីខ្លះទៅ?

មៀនៈ អ្នកទៅជាមួយ?

ដារ៉ាៈ បាទ!

មៀនៈ អ្នកទៅជាមួយដែលជិតស្និតជាងគេ ប្រចហ្នឹងហើយ តាំងពីនៅភូមិជាមួយគ្នា ហើយទៅក៏ទៅជាមួយគ្នាដែរ ។ បន្ទាប់ម៉ោ មឿន នៅកងនេះ, មឿន ងាប់បាត់ហើយ, មិនងាប់មិនដឹងអីទេ តែជំនាន់ប៉ុល ពតគេចាប់ ។

ខស្នានៈ មឿន នៅភូមិអី?

មៀនៈ នៅភូមិគោក, ឃុំពានី ។ ហ្នឹងសុទ្ធតែមិត្តជិតស្និតជាមួយខ្ញុំហើយ ។

ដាវ៉ាៈ ហើយមាននរណាទៀត?

មៀនៈ បន្ទាប់មាន ផៃ, ផៃ នៅពានីដែរ ។

ខស្នាានៈ នៅរស់ទេ ផៃ ហ្នឹង?

មៀនៈ ផៃ នៅរស់រាល់ថ្ងៃ ជួបគ្នារាល់ថ្ងៃ, ជួបគ្នាម្សិលមិញ ម្សិលម្ងៃ មិនមែនម្សិលមិញទេ ។

ខស្នាានៈ គាត់នៅជាមួយគ្នារហូត?

មៀនៈ ផៃ, នៅជាមួយគ្នារហូត ។

ដាវ៉ាៈ រហូតដល់បែក៧៩?

មៀនៈ បាទ, ដល់បែក៧៩, គ្រាន់តែថា នៅកងខុសគ្នា ផ្នែកខុសគ្នា ។

សុជាៈ ហើយពូផៃ គាត់ពេលបែក៧៩ម៉ោ គាត់ម៉ោនៅភូមិហ្នឹងវិញ ឬគាត់ទៅណាវិញ?

មៀនៈ នៅពានី គាត់បែកគ្នាតាំងពីឆ្នាំ៧៩នេះ រត់ចុះទៅនៅព្រៃ នៅភ្នំតាម៉ៅ ដល់ពេលនេះគេម៉ោផ្ទុះមុនម៉ោ ខ្ញុំនៅព្រៃណុងនៅឡើយទេ ។

ដាវ៉ាៈ ហើយចុះពូ ដល់ពេលទៅបឹងទំពុនឆ្នាំ៧៥ គេឲ្យចិញ្ចឹមជ្រូក ហើយដល់ក្រោយមកទៀតគេ ឲ្យធ្វើអីទៀតទៅ?

មៀនៈ ចិញ្ចឹមជ្រូកមិនយូរទេ ប្រហែលជាកន្លះខែប៉ុណ្ណឹងទេ ។

ដាវ៉ាៈ ហើយទៅណាទៅនៃទៀតទៅ?

មៀនៈ គេឲ្យទៅនៅតាមស្ទឹង កាលណឹងគេហៅសាលាបច្ចេកទេស ហាត់ក្បួនយោធា ។ លត់ដំអាស្ទឹងតាខ្មៅទៅលិចនោះ ។

ដាវ៉ាៈ គេហៅស្ទឹងអីគេ?

មៀនៈ ស្ទឹងតាខ្មៅ ហ្នឹងហើយ, នៅតាមដីងស្ទឹង ។

ដាវ៉ាៈ ហាត់ប៉ុន្មានខែ?

មៀនៈ ហាត់ប្រហែលជា ៤ខែ។

ដារ៉ាៈ អ្នកណាគេអ្នកបង្ហាត់?

មៀនៈ បង្ហាត់ មានតែយ៉ែម, តាណោ។

ដារ៉ាៈ គេបង្រៀនអីខ្លះទៅនៅក្នុងនោះ?

មៀនៈ បង្រៀនពីនយោបាយ, បង្រៀនពីក្បាច់ក្បួនយោធា ក្បាច់បុរាណទាំងអស់ រៀនចាប់។

សុជាៈ ចុះបង គេបង្រៀននយោបាយ គេបង្រៀនថា យ៉ាងម៉េចខ្លះ?

មៀនៈ នយោបាយនិយាយពីមាគ៌ាត្រឹមត្រូវ មាគ៌ាស្អីគេ ខ្ញុំពិបាកនិយាយដែរ នយោបាយគេដឹកនាំប្រទេសផ្តាច់ការរបស់គេហ្នឹង។ ទៅនៅហ្នឹងលត់ដំ៤ខែហ្នឹង គឺអ្នកខ្លះទ្រាំមិនបានរត់គេចពីណុងខ្លះ អ្នកខ្លះធ្វើពុតឈឺ ពុតអីចឹងទៅ។ ទៅហាត់គ្នាច្រើនណាស់ ២ឡានទៅទាំងអស់គ្នាហ្នឹង តែអ្នកដែល នៅចេះតែទ្រាំបាន ប្រហែលជា៤-១០-២០នាក់ទេដែលចេះនៅទ្រាំបាន។

សុជាៈ ទៅនៅតាខ្មៅទៅនៅខាងណាស្ទឹងបង?

មៀនៈ នៅខាងលិច នៅអមស្ទឹងហ្នឹង។

ដារ៉ាៈ ដល់ពេល អ្នកណាគេប្រធានសាលា?

មៀនៈ តា យែមហ្នឹងហើយ។

ដារ៉ាៈ ហើយដល់ពេលហាត់ទាហានចប់ហើយ គេបញ្ជូនទៅណាទៀត?

មៀនៈ ចេញពីហ្នឹងហើយ គេឲ្យបញ្ជូនឲ្យម៉ោនៅផ្សារតាខ្មៅ នៅយាម ម៉ោឲ្យយាមអ្នកទោសនៅផ្សារតាខ្មៅ, យាមអ្នកទោសដើរស្រោចបន្លែ។

ដារ៉ាៈ ផ្សារតាខ្មៅ, ផ្សារតាខ្មៅរាល់ថ្ងៃនេះ?

មៀនៈ កាលណឹងវាអត់មានគេហៅផ្សារចាស់ពីដើមនៅខាងនេះ គេធ្វើរោងធ្វើអីចឹង ធ្វើរបងការពារអ្នកទោស។

ដារ៉ាៈ បងការពារអ្នកទោស គេឲ្យស្លៀកពាក់យ៉ាងម៉េច មានកាំភ្លើងអីដែរ?

មៀនៈ ស្លៀកពាក់របៀបខ្មែរក្រហម កាំភ្លើងធម្មតា យាមការពារអ្នកទោសដើរស្រោចបន្លែ។

សុជាៈ បងដឹងថា អ្នកទោសហេតុអីបានគេចាប់យកមកធ្វើអ្នកទោស?

មៀនៈ កាលពីស្របក់ហ្នឹង គេថា ក្បត់ជាតិហ្នឹងហើយបានគេចាប់យកមក។

ដារ៉ាៈ ភាគច្រើនអ្នកទោសនៅក្នុងណឹង ម៉ោពីខាងណាបង?

មៀនៈ កាលនៅគាឡោហ្នឹង ខ្ញុំអត់សូវដឹងដែរទេ។ គេអត់មានឲ្យសួរនាំអីទេ យាមដឹងតែការពារ យាម ខ្លាចតែរឿងរួច បើរួចគឺស្លាប់ខ្លួនឯង មានតែប៉ុណ្ណឹងទេ។ ការពារកុំឲ្យតែរត់រួច ធ្វើម៉េចកុំឲ្យ គេសម្លាប់ខ្លួនបាន ឬរត់រួច ប៉ុណ្ណឹងបានហើយ។

ខស្មានៈ ហើយអ្នកទោសគេឲ្យធ្វើការម៉េចដែរបង?

មៀនៈ គេធ្វើការធម្មតាអីចឹង ដល់ម៉ោងគេឲ្យស្រោចទឹក ស្រោចបន្លែអីចឹងទៅ។ ស្រោចពី ម៉ោង៧ ដល់ម៉ោង១០ ម៉ោង៩អីចឹងទៅ ឲ្យចូលកន្លែងវិញ, ចូលបន្ទប់គេទៅ។

ដារ៉ាៈ ហើយនៅក្នុងបន្ទប់ បងធ្លាប់បានយាមនៅតាមបន្ទប់តាមអីដែរ?

មៀនៈ ខ្ញុំនៅគាឡោ បានប្រហែល៣ខែ បានខ្ញុំម៉ោនៅកន្លែងគុកធំ កន្លែងប៉េអែស(PS) កន្លែង នៅផ្សារថ្មី កន្លែងគុកពីដើម គុកចាស់។

ដារ៉ាៈ ប៉េអែស(PS)ផ្សារថ្មី?

មៀនៈ គុកចាស់ពីដើម ខ្ញុំឮគេហៅគុកចាស់ពីដើម, ខ្ញុំអត់ដឹងដែរ, នៅខាងត្បូងជាប់ផ្សារថ្មី។ មិនមែនផ្សារថ្មីឥឡូវទេ ផ្សារថ្មីបយរាណពីដើម, កាលណឹងផ្សារថ្មីគេលប់ចោល គេដាក់ សុទ្ធតែឡាន, អាឡានខូចគេដាក់ពេលម៉ាផ្សារហ្នឹង។ កាល៧៩រំដោះហើយ គេយក ឡានខូចៗ យកទៅគរ ចោលពីលើគ្នា។

ដារ៉ាៈ ប្រហែលជាខែណាបង ដែលបងផ្លាស់ពីយាមអ្នកទោសនៅគាឡោ ផ្សារគាឡោ ម៉ោ កន្លែងប៉េអែស(PS) ?

មៀនៈ មិនដឹងខែប៉ុន្មានទេ, ភ្លេចហើយ យូរហើយ ២០ឆ្នាំជាងហើយ។

ដារ៉ាៈ ចុះមកដល់កន្លែងគុក ប៉េអែស(PS)ផ្សារថ្មីហ្នឹង?

មៀនៈ គេឲ្យដើរយាមអ្នកទោសតាមបន្ទប់។

ដារ៉ាៈ បន្ទប់យ៉ាងម៉េចបង មានបន្ទប់ច្រើនទេ?

មៀនៈ បន្ទប់ច្រើនបន្តគ្នា ម៉ាផ្ទះមានបន្ទប់៧-៨អីចឹងទៅណា៎ គេវៃធ្វើបន្ទប់ប៉ុនគ្រែនេះឲ្យមនុស្ស ដេកនៅហ្នឹង។

ដារ៉ាៈ យាម មានផ្លូវវេនយាមវេនអីដែរ?

មៀនៈ ម៉ាយប់ហ្នឹង ដូរពីរយាម ។ យើងយាមពីម៉ោង៧ ដល់ម៉ោង ១២ ឈប់ ដល់នេះដាស់ គេផ្លាស់ដល់ភ្លឺ ។

ដារ៉ាៈ បងមានដែលស្គាល់ឈ្មោះអ្នកទោសណាមួយ ពេលបងយាមមានស្គាល់អ្នកទោសណាមួយទេ?

មៀនៈ អាអ្នកស្គាល់តែម្ដងវា ចេះតែស្គាល់ហើយកាលណុងនោះ តែឥឡូវវាភ្លេចអស់ហើយ ។ តែនៅស្គាល់ អាមឿន នៅគោកដែលខ្ញុំថា ហ្នឹងណា៎, ហ្នឹងមួយ កាលទៅជាមួយគ្នា ទៅជាមួយគ្នា រួចគេចាប់ ។ ទៅជាមួយគ្នាពីអគ្គភាពជាមួយគ្នានៅគោកទៅពីទ័ពស្រុក ជាមួយគ្នា គេចាប់, ចាប់ដាក់ គុកហ្នឹងដដែល ។

ខស្នានៈ ចុះដាក់អីចឹងអាចនិយាយលេងឲ្យនេះឲ្យនោះបានទេ?

មៀនៈ គ្មានឲ្យទៅសួរទេ គ្រាន់តែឲ្យទៅអឺតមើល តែសួរអត់ហ៊ានសួរផង យើងខ្លាចគេរករឿង ។

ខស្នានៈ ពីណាប្រធានគុកនៅ ប៉េអែស(PS) ?

មៀនៈ ប្រធានគុកនៅ ប៉េអែស(PS) តាឌុចហ្នឹងហើយ ។ ពីដើមឈ្មោះ ចិនអ៊ីវ, ឥឡូវគេហៅ តាឌុចនៅជាប់គុកជាមួយតាម៉ុករាល់ថ្ងៃនេះ ។

ខស្នានៈ បងដែលដឹងដំណឹងពីការជាប់គុកហ្នឹងដែរ ម៉េចបានឮ?

មៀនៈ ឮគ្រាន់តែឮតែខ្ញុំមិនបានទៅជិតទេ ។

ខស្នានៈ ហើយចុះបន្ទាប់ពីតាឌុចមានអ្នកណាទៀត?

មៀនៈ តាឌុច តាហ៊ឹ ។

ខស្នានៈ នៅ ប៉េអែស(PS) ?

មៀនៈ បាទ!

ខស្នានៈ បន្ទាប់ម៉ោទៀត អ្នកធំៗ ?

មៀនៈ បន្ទាប់ម៉ោទៀត មានតែសមាជិក មាន ចាន់ ។

ដារ៉ាៈ ពេលបងយាមអ្នកទោសនៅគុកនៅតាខ្មៅ អ្នកណាប្រធានបង?

មៀនៈ នៅតាខ្មៅ កាលណឹង តាផល, តាផល តាដួ, គាត់ប្រធាន អនុប្រធាន ។ ដល់ពេលដក ម៉ោ ប៉េអែស(PS) គាត់ម៉ោដែរ, ខ្ញុំក៏ម៉ោ គាត់ក៏ម៉ោ ។

ខស្នានៈ ហើយចុះគុកនៅតាខ្មៅរំសាយចេញវិញ ឬនៅដដែល?

មៀនៈ អត់ទេ នៅដដែល តែគេផ្លាស់អ្នកការពារនៅហ្នឹង ។ គេបញ្ចេញពី ប៉េអែស(PS) ធំហ្នឹងទៅ ទៅឲ្យនៅតាខ្មៅនៅណុង, នៅតាខ្មៅណុង ។ គេសួរចម្លើយសួរអីនៅកន្លែងគុកធំចប់ គេបញ្ជូនទៅ នៅតាខ្មៅ ។

ដារ៉ាៈ បងគ្រាន់តែជាអ្នកការពារ ម៉េចបងអាចដឹងថាគេសួរចម្លើយម៉េចៗ នៅប៉េអែស(PS) ?

មៀនៈ គុកនៅ ប៉េអែស(PS) គេអត់ឲ្យយើងដឹងទេ ។ គឺយើងអ្នកយាម ដល់ពេលគេសួរ គេម៉ោ គេហៅគេម៉ោ គេហុចឈ្មោះឲ្យយើងមួយស្លឹក ឲ្យទៅយកឈ្មោះណាឲ្យគេ យកពីហ្នឹងម៉ោគេយកទៅ សួរនៅបន្ទប់គេទេ ។

ដារ៉ាៈ ហើយអាសំបុត្រដែលគេដាក់ឲ្យយើងទៅយកអ្នកទោសហ្នឹង បងដែលឃើញទេ? គេឲ្យបង ផ្ទាល់តែម្តង, សំបុត្រហ្នឹងណា?

មៀនៈ សំបុត្រហ្នឹង គេដាក់បញ្ជីអីចឹង ។ អ្នកមួយមកយកអីចឹង គេកត់ឈ្មោះគេម៉ោយកឈ្មោះ, ឧបមាថា ឈ្មោះខ្ញុំអីចឹងណា៎ ឈ្មោះអីចឹងណា៎ ទៅយកឈ្មោះយកមកសួរចម្លើយ គេកត់ទាំងគេ គេកត់ទាំងឈ្មោះអ្នកទោស ។

ដារ៉ាៈ ហើយបងកាន់អាហ្នឹងទៅយកអ្នកទោសទៅ?

មៀនៈ ហ្នឹងហើយ ។

ដារ៉ាៈ ហើយហៅចេញម៉ោ យកឲ្យទៅអ្នកណាទៅ?

មៀនៈ យកទៅឲ្យអ្នកគេម៉ោយកហ្នឹងហើយ ។

ដារ៉ាៈ តាមបងធ្លាប់ទៅយកអ្នកទោសហ្នឹង បងធ្លាប់ទទួលសំបុត្រហ្នឹងពីអ្នកណាខ្លះ អាសំបុត្រដែលឲ្យទៅ...បញ្ជី?

មៀនៈ អាហ្នឹងវាភ្លេចថ្ងៃ វាចាំមិនបានទេ ។ ឈ្មោះអ្នកសួរចម្លើយ កាលណុងវាមានតែ ចាន់, តាហ៊ិ, តាប៊ុន, នន, ឈ្មោះច្រើនគ្នាណាស់ ។

ដារ៉ាៈ ឈ្មោះដែលបងរៀបរាប់អម្បាញ់មិញ សុទ្ធតែធ្លាប់មានបញ្ជីឲ្យទៅយកអ្នកទោសម៉ោសួរចម្លើយអីចឹងឬ?

មៀនៈ ហ្នឹងហើយ ។

ដារ៉ាៈ មានដែលឃើញ ឌុច, មានដែលឃើញបញ្ជីឈ្មោះរបស់ ឌុច ដែលឲ្យបងគាត់ទៅយក..?

មៀនៈ ឌុច គាត់អត់ដែលនេះទេ គាត់គ្រាន់តែបញ្ជានៅក្រោយនៅផ្ទះគាត់នោះទេ។ កាលណាគេអ្នកសួរចម្លើយវ៉ា ឧបមាថា សួរចម្លើយហ្នឹងមិនចេញ ឬមួយក៏ចង់ពិភាក្សាអី ពិភាក្សាជាមួយគាត់ គាត់អត់មានដែលម៉ោសួរទេ។ បើតាហ៊ា គាត់អាចចូលជួយសួរបាន។ តាហ៊ាមានចូលមកកន្លែងសួរ ចម្លើយកន្លែងអីចឹង កាលណាដែលគេសួរថា វ៉ាសួរចម្លើយអត់ឆ្លើយអីចឹង គាត់ម៉ោជួយសួរ។

ដារ៉ាៈ ចុះបងអាចរៀបរាប់បានកន្លែងគុក ប៉េអែស(PS) នៅត្រង់ណាឲ្យច្បាស់លាស់នៅផ្សារថ្មី?

មៀនៈ ផ្សារថ្មីនៅជ្រុងអីចឹងចេះ, គុក ប៉េអែស(PS) នៅខាងលិចឆៀងខាងត្បូង។

ឧស្មានៈ ខាងបេនឡានសព្វថ្ងៃហ្នឹង?

មៀនៈ មិនត្រង់ណាទេ បើគេរើផ្សារថ្មីអស់បាត់ហើយ, ខ្ញុំទៅលែងស្គាល់ហើយ ឥឡូវហ្នឹងនោះ។

ដារ៉ាៈ តែគ្រាន់តែដឹងថា នៅខាងលិចឆៀងខាងត្បូងផ្សារថ្មី, ផ្សារធំថ្មីយើងឥឡូវហ្នឹង?

មៀនៈ ផ្សារចាស់ពីដើម មិនមែនផ្សារសព្វថ្ងៃហ្នឹងទេណា។ ផ្សារចាស់ ឥឡូវណឹងគេរើបាត់អស់ហើយ។ ឈ្មោះផ្សារថ្មីពីដើម មិនមែនផ្សារថ្មីឥឡូវនេះទេ។

ឧស្មានៈ សព្វថ្ងៃ កន្លែងគុកហ្នឹងមានដឹងថា គេយកធ្វើអីទេ ជាផ្ទះប្រជាជន ឬកន្លែងអី?

មៀនៈ អត់ដឹង អត់ដែលទៅ។

ដារ៉ាៈ ជិតមាត់ទន្លេទេបង?

មៀនៈ អត់ជិតទេ កណ្តាលក្រុង។

ដារ៉ាៈ បើបងនិយាយផ្សារថ្មី វ៉ាច្រឡំនឹងផ្សារថ្មីធំឥឡូវ?

មៀនៈ ខ្ញុំវ៉ាច្រឡំ អីចឹងបានថា ផ្សារថ្មីធំឥឡូវ មិនដឹងគេធ្វើថ្មី, ដឹងកន្លែងគេធ្វើ តែមិនមែនកន្លែងផ្សារថ្មីពីដើមនោះទេ។ ផ្សារថ្មីអាកន្លែងពីដើម អាកន្លែងផ្សារចាស់នៅជ្រុងអីចេះ, នៅជិតវត្ត កោះ, ស្គាល់វត្តកោះទេ?

ដារ៉ាៈ ស្គាល់។

មៀនៈ វ៉ានៅទល់នឹងវត្តកោះហ្នឹងហើយ។

ឧស្មានៈ ឆ្លងថ្នល់ម្ខាងម្នាក់?

មៀនៈ ហ្នឹងហើយ ទល់មុខផ្លូវកណ្តាលអីចេះ កន្លែងគុកវ៉ាអីចេះវត្តកោះវ៉ាអីចេះ។

ដារ៉ាៈ ទល់មុខនឹងវត្តកោះហ្នឹងតែម្តង អាផ្ទះល្វែងទល់មុខវត្តកោះណឹងឬ?

មៀនៈ ផ្ទះអត់ល្វែងទេ, ផ្ទះដែលគេដាក់អ្នកទោសនោះ ។ ផ្ទះរាងមូលឡើងលើពជាន់ ។

ដារ៉ាៈ អ៊ីចឹងបងមកពីកន្លែងបឹងទំពុនចិញ្ចឹមជ្រូក បងផ្លាស់មកកន្លែងហាត់ទាហាននៅតាខ្មៅ ហើយចេញពីទាហាននៅតាខ្មៅមកយាមអ្នកទោសនៅតាខ្មៅដែរ តែគុកនៅតាខ្មៅ ហើយក្រោយមកបាន ដូរមក ។

មៀនៈ ម៉ោនៅ ប៉េអែស(PS) មួយឆ្នាំៗរហូតដល់(១៩)៧៦ ។ ពីឆ្នាំ៧៦-៧៧ ផ្លាស់ពីប៉េអែស(PS) ម៉ោនៅកន្លែងសាលាទួលស្វាយព្រៃ ដែលគេហៅគុកទួលស្លែងសព្វថ្ងៃនេះ ។

ដារ៉ាៈ អ៊ីចឹងនៅក្នុងគុក ប៉េអែស(PS) ហ្នឹង បងធ្លាប់ស្គាល់ឌុច នៅហ្នឹងដែរ?

មៀនៈ គាត់នៅហ្នឹងដែរ គាត់ប្រធាន, គាត់នៅហ្នឹង ។

ដារ៉ាៈ ហើយពេលសួរចម្លើយសួរអី បងមានដែលឮការសួរចម្លើយហ្នឹងទេ ការសួរចម្លើយអ្នកទោសបងមានដែលឃើញទេ?

មៀនៈ ដែល, ចាំមើលខ្ញុំនិយាយឲ្យចប់រឿងខ្ញុំ ។ ខ្ញុំម៉ោពីណុងម៉ោ ខ្ញុំផ្លាស់ពីយាមអ្នកទោស គេឲ្យម៉ោនៅរៀនវៃអក្តុលីលេខ ។

ដារ៉ាៈ រៀននៅម្តុំណា?

មៀនៈ នៅទួលស្វាយព្រៃហ្នឹង នៅតាមផ្ទះខាងត្បូងទួលស្វាយព្រៃហ្នឹង ។

ដារ៉ាៈ ដែលអត់ទាន់ម៉ោពី ប៉េអែស(PS) ?

មៀនៈ ម៉ោពី ប៉េអែស(PS) ហើយ ។ ហ្នឹងគេរើពីកន្លែងចាស់ពី ប៉េអែស(PS) ហ្នឹងម៉ោ មកនៅទួលស្វាយព្រៃ ។

ដារ៉ាៈ អ៊ីចឹងនៅពេលដែលមានគុកនៅ ប៉េអែស(PS) គុកនៅទួលស្វាយព្រៃគេហៅគុកទួលស្លែងរាល់ថ្ងៃហ្នឹងមាននៅ?

មៀនៈ នៅទេ, កាលនៅ ប៉េអែស(PS) អត់ទាន់មានទេ, គឺរើពីហ្នឹងទាំងអស់តែម្តង ម៉ោនៅទួលស្វាយព្រៃ ។

ដារ៉ាៈ រើនៅឆ្នាំណាបង?

មៀនៈ ចុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ហើយ ។ អានេះខ្ញុំចាំមិនប្រាកដ គ្រាន់តែស្មានៗទេណា ។

ដារ៉ាៈ គ្រាន់តែដឹងថា ពេលគុក ប៉េអែស(PS) ហ្នឹងហើយ បានរើម៉ោទួលស្វាយព្រៃ ហើយកាលពីមានគុក ប៉េអែស(PS) ហ្នឹង គុកទួលស្វាយព្រៃទួលស្លែងអត់ទាន់មានទេ?

មៀនៈ អត់មានទេៗ គេវើពីណុងម៉ោទាំងអស់គ្នាអីចឹងតែម្ដង ។

ដារ៉ាៈ អីចឹងបងនិយាយតទៀតទៅ ទៅរៀនអក្ខរលីលេខម៉េចនោះ?

មៀនៈ ខ្ញុំរៀនវើអក្ខរលី(លេខ) ចម្លងឯកសារពីអ្នកទោស ចម្លើយអ្នកទោសតែម្ដង ។

ដារ៉ាៈ ឈប់យាម?

មៀនៈ ឈប់យាមហើយ ។

ដារ៉ាៈ ដល់ពេលចម្លើយអ្នកទោស, ពេលរៀនចេះវើអក្ខរលីលេខហើយ ចម្លើយអ្នកទោសបងធ្វើយ៉ាងម៉េច?

មៀនៈ ចម្លើយគឺចម្លងតាមឯកសារអ្នកទោសសរសេរតែម្ដង ។

ដារ៉ាៈ ភាគច្រើនអ្នកទោសសរសេរ ឬក៏មានអ្នកសរសេរជំនួស?

មៀនៈ ជួនកាលអ្នកទោសចេះសរសេរគឺសរសេរខ្លួនឯងបណ្ដោយ ។ បើអ្នកទោសអត់ចេះសរសេរគឺអ្នកសួរចម្លើយសរសេរ, សរសេរតាមអ្នកទោសនិយាយ ។

ដារ៉ាៈ និយាយហើយម៉ោ យកមកឲ្យខាងបងវាយអក្ខរលីលេខ?

មៀនៈ បាទ, វើអក្ខរលីលេខចម្លង ។

ដារ៉ាៈ ហើយដល់ពេលវើហើយ បងយកជូនទៅខាងណាទៀត?

មៀនៈ បញ្ជូនទៅមេ ទៅតាឌុចហ្នឹងហើយ ។

ដារ៉ាៈ អីចឹងពេលបងផ្លាស់ម៉ោគុកទួលស្លែង បងលែងអ្នកយាម?

មៀនៈ លែង,

ដារ៉ាៈ អ្នកវើអក្ខរលីលេខរហូតតែម្ដង?

មៀនៈ វើទល់ដល់៧៩, គេបញ្ជូនម៉ោឲ្យខ្ញុំរៀនសួរចម្លើយដែរ ។ ចេញពីណុងម៉ោគេឲ្យម៉ោរៀនសួរចម្លើយ ។ ខ្ញុំបានសួរដែរ តែបានសួរតិចតួច ។ សួរបាន២-៣ខែ ប៉ុណ្ណឹង ។

ឧស្មានៈ បានប៉ុន្មាននាក់ដែរ, ២-៣ខែ?

មៀនៈ ២-៣ខែ សួរអត់រួចម្នាក់ផងក៏មានដែរ ។ ចម្លើយគេសរសេរវិលចុះវិលឡើង ។

ដារ៉ាៈ បងមានចាំឈ្មោះអ្នកទោសណាមួយ(ដែល)សួរចម្លើយទេ?

មៀនៈ ចាំ, តែគ្រាន់ថាវាមិន...

ដារ៉ាៈ គ្រាន់តែចាំឈ្មោះ?

មៀនៈ ចាំឈ្មោះម្នាក់នៅខាងបាត់ដំបង, គាត់នោះពីដើមធ្វើសាស្រ្តាចារ្យ ខាងគណៈតំបន់ ។

ដារ៉ាៈ ឈ្មោះអីគេបង?

មៀនៈ ឈ្មោះ ប៉ែន សាម៉ន ។

ដារ៉ាៈ បងស្គាល់ផ្ទាល់តែម្តង?

មៀនៈ បាទ!

ដារ៉ាៈ កាលណឹងប៉ែន សាម៉នចោទថា យ៉ាងម៉េចបានយកមកសួរចម្លើយ?

មៀនៈ មិនទេ, គេចោទថា ក្បត់ជាតិនោះហើយ ។ ពីដើមគាត់ធ្វើសាស្រ្តាចារ្យនៅភ្នំពេញ ដល់ពេកនេះ គាត់ជាផ្នែកក្នុងរបស់ខ្មែរក្រហម ។ គាត់នៅភ្នំពេញទល់បែក៧៥ បានគាត់ទៅធ្វើគណៈតំបន់ តំបន់សាមប៉ុន្មានទេខាងភូមិភាគពាយព្យនេះ, ខ្ញុំភ្លេចអស់ហើយ ចាំវាមិនច្បាស់ទេ ។

ដារ៉ាៈ ក្នុងពេលសួរយើងធ្វើយ៉ាងម៉េចទៅបង ពេលសួរចម្លើយ?

មៀនៈ មុនដំបូងសួរពីប្រវត្តិ ដូចគាត់(សំដៅលើខស្នាន)សួរខ្ញុំអីចឹងដែរ ។ សួរដំណើរទំនងអីចឹង, ពេលចុងបញ្ចប់សួរថា ម៉េចបានអង្គការចាប់យើងម៉ោ? ដល់វាថា ខ្ញុំក្បត់អង្គការបានគេចាប់ខ្ញុំម៉ោ ក្បត់ធ្វើអីខ្លះ រៀបរាប់ម៉ោ, ពីប្រវត្តិឯងក្បត់ ។ ដល់ពេលនេះវាអត់ព្រម ។ ឈ្មោះ ប៉ែន សាម៉ន អត់ឆ្លើយទេ ។ ខ្ញុំសួរយូរណាស់ សួរប្រហែលជា៧-៨ថ្ងៃ បានខ្ញុំបញ្ជូនឲ្យតាហ៊ីជួយសួរ ។ ដល់តា ហ៊ីម៉ោសួរ គាត់សួរគាត់វ៉ៃគាត់អីដែរ, គាត់វ៉ៃដេរអីចឹងដែរ បានវាឆ្លើយ ។ ឆ្លើយម៉ោគាត់ប្រគល់ ឲ្យខ្ញុំវិញ ។ ខ្ញុំមើលថែវាដើម្បីសួរបន្តទៀត, កត់ពីចម្លើយ កត់ពីអីហ្នឹងទៅ ។ ខ្ញុំសួរបាន២-៣នាក់ ដែរតែខ្ញុំចាំឈ្មោះតែម្នាក់ហ្នឹង ក្រៅពីហ្នឹងភ្លេចអស់ ។

ដារ៉ាៈ ហេតុអីបានបងចាំឈ្មោះហ្នឹងជាងគេ?

មៀនៈ ហ្នឹងរៀនសួរមុនគេ រៀនដួរដំបូងហើយហ្នឹង ។ អត់ចេះសួរទេ ។

សុជាៈ អីចឹងអ្នកដែលក្រោយៗដែលបងសួរណឹង គេសុទ្ធតែឆ្លើយនឹងសំណួរបង?

មៀនៈ ឆ្លើយតែម្តង, អត់បាច់វ៉ៃ ។ បើឈ្មោះនៅតាមរោងចក្រ សួរអ្នកអនុប្រធានរោងចក្រ ឈ្មោះអីភ្លេចអស់បាត់ហើយ ខ្ញុំអត់ចាំយូរហើយ ។

ខស្នានៈ ពេលអ្នកទោសឆ្លើយណឹង ឯកសារហ្នឹងតើបងមានស៊ីញ៉េ មានអីទេ?

មៀនៈ ឯកសារហ្នឹងគឺយើងសរសេរចប់ យើងស៊ីញ៉េផ្តិតមេដៃទាំងអ្នកទោស ទាំងអីទាំងអស់ហ្នឹងហើយ ។ ហើយពេលយើងសួរចម្លើយអ្នកទោសថតតាំងពីសម្លេងអ្នកសួរ សម្លេងអ្នកឆ្លើយទាំងអស់ ។

ខស្នាៈ ហើយចុះបងចម្លងឯកសារអត្ថលិខិតហ្នឹង មានស៊ីញ៉េដាក់ឈ្មោះបងទេ?

មៀនៈ ស៊ីញ៉េ, ស៊ីញ៉េដាក់ក្របខាងក្រៅទេណា ។

ខស្នាៈ ដាក់ឈ្មោះយ៉ាងម៉េចទៅ?

មៀនៈ ដាក់ឈ្មោះអ្នកចម្លងឯកសារអីចឹងទៅ ។

ដារ៉ាៈ ហើយបងកាលជំនាន់ធ្វើជាអ្នកសួរចម្លើយនៅទួលស្លែងនោះ បងដាក់ឈ្មោះអីគេ ឈ្មោះដដែល?

មៀនៈ ឈ្មោះដដែល, ខ្ញុំអត់មានប្រែទេ, ឈ្មោះ ឡាច មៀន ដដែលហ្នឹង ។

ដារ៉ាៈ ដល់ពេលសួរហើយ ចម្លើយសារភាពដែលបងបានទទួលហើយ បងផ្ញើទៅខាងណាអីខាងនៃទៀត?

មៀនៈ ផ្ញើទៅតាម ទៅឲ្យប្រធានគេពិនិត្យ ទៅតាមរយៈទៅតាហ៊ិអីចឹងទៅ, តាហ៊ិពិនិត្យរួចទៅតាឌុចអីចឹងទៅ, តាឌុចអត់ដឹងផ្ញើទៅណាទៀត ខ្ញុំអត់ដឹងទេ ។

ដារ៉ាៈ មានដែលផ្ញើត្រឡប់មកបងវិញទេ?

មៀនៈ មាន, ដែលធ្វើឧបមាថា ឆ្លើយដាក់ឈ្មោះណាដែល, កាលណឹងឆ្លើយដាក់ឈ្មោះតាវ៉ន វេត, ពីដើម វ៉ន វេត មិនអនុប្រធានប៉ុល ពត ។ ឆ្លើយដាក់តា វ៉ន វេត គេបញ្ជូនឯកសារហ្នឹង មកវិញ ។ ម៉ោវិញឲ្យបញ្ជាក់ម្តងទៀត បញ្ជាក់ឲ្យច្បាស់ ។ ដល់ពេលនេះបានសួរវាសារចុះឡើង ទៀត ។

ដារ៉ាៈ ហើយដល់ពេលបងចេះសួរចម្លើយណឹង ទៅរៀនសួរចម្លើយ?

មៀនៈ រៀនទៅនៅជាមួយគេ ដឹកអ្នកទោសយកទៅកាន់ អង្គុយមើលគេសួរ ជួយកត់ត្រាកត់អីអង្គុយកៅអីមួយ គេសួរអ្នកសួរអង្គុយអីចឹង ។

ដារ៉ាៈ គេមានគោលការណ៍សម្រាប់សួរទេ នៅទួលស្លែង គេមានគោលការណ៍សម្រាប់សួរចម្លើយអ្នកទោសទេ?

មៀនៈ គេបង្រៀនយើង គេមាន, គេមានគោលការណ៍បង្រៀនមុនដំបូងគេសួរពីអី, សួរពីប្រវត្តិ សួរពីប្រវត្តិសួរពីដំណើរដែលក្បត់អង្គការអីចឹងទៅណា, អាណឹងគេរៀន...

សុជាៈ ពេលពូដែលទៅអង្គុយរៀនមើលគេសួរចម្លើយ ពីណាគេអ្នកដែលសួរចម្លើយ?

មៀនៈ កាលខ្ញុំទៅរៀនហ្នឹង ឈ្មោះ កាក់, អ្នកសួរ ។

សុជាៈ ហើយពេលដែលគេសួរ គេធ្វើយ៉ាងម៉េចខ្លះ?

មៀនៈ សួរ, គេសួរពីប្រវត្តិអីចឹងទៅដល់ពេលនេះបើសួរ អ្នករឹងរូសទៅគេវ៉ៃ ជួនគេវ៉ៃ ជួនកាលគេឆក់ខ្សែភ្លើង ។

ដារ៉ាៈ បង នៅក្នុងទារុណកម្មនៅទួលស្លែង ដែលបងធ្លាប់ជួបប្រទះ មានទារុណកម្មអីខ្លះធ្វើទៅលើអ្នកទោស?

មៀនៈ ទារុណកម្ម មានតែវ៉ៃ ឆក់ខ្សែភ្លើង ហើយនិងច្រកស្បោងផ្លាស្ទិកត្រឹមក អាហ្នឹងមាន ។

ដារ៉ាៈ ដល់ពេលសួរចប់ហើយ អ្នកទោសបញ្ជូនទៅណាវិញ?

មៀនៈ អ្នកទោសយកទៅដាក់កន្លែងគេវិញ ។ យើងយកមកសួរ យើងសួរថ្ងៃហ្នឹងយកទៅដាក់ក្នុងបន្ទប់គេវិញទៅ ។

ដារ៉ាៈ មានកងសួរប៉ុន្មានកងទៅបង?

មៀនៈ កងសួរចម្លើយមានតែមួយកងគ្នាប្រហែលជាមិនដល់២០នាក់ផង ប្រហែល១៥(នាក់) ។

សុជាៈ បងអាចរៀបរាប់ឈ្មោះខ្លះទេបង?

មៀនៈ ឈ្មោះចាំ ចាំខ្លះ ភ្លេចខ្លះ ។

ដារ៉ាៈ អ្នកសួរ ឈ្មោះអីខ្លះទៅ?

មៀនៈ អ្នកសួរមេជាងគេ មាន តាចាន់, ប៉ុន, ហើយបន្ទាប់មកមេពួកខ្ញុំឈ្មោះ នន, ឈ្មោះណាន, ឈ្មោះ ទិត ។

ដារ៉ាៈ ដល់ពេលក្រោយមកទៅ អ្នកទាំងអស់ហ្នឹងទៅណាអស់ទៅ?

មៀនៈ ដល់ពេលយួនចូលវ៉ៃបែកភ្នំពេញ គាត់រត់ចេញពីភ្នំពេញម៉ោធ្វើទ័ពទាំងអស់គ្នា, បែកគ្នានៅឯខាងលិចខេត្តង ។

សុជាៈ ធ្វើទ័ពអីគេបង?

មៀនៈ ធ្វើទ័ពខ្មែរក្រហមដដែលហ្នឹង វៃជាមួយយួន។ កាលណាហ្នឹងយួនចូលស្រុក មិនចូលទ័ពវៃជាមួយយួន។

ដារ៉ាៈ ចុះបងអាចរៀបរាប់ឲ្យបានច្បាស់បានទេ ចាប់ផ្ដើមមុនដំបូងពីការទៅយកអ្នកទោស ហើយយកអ្នកទោសមកសួរ សួរហើយកត់អីយ៉ាងម៉េចៗរបៀបយកអ្នកទោសមកសួរ បងរៀបរាប់បានទេ? ឧទាហរណ៍ថា ឥឡូវយើងយកអ្នកទោសម៉ោសួរហើយ ហើយយកទៅកន្លែងណា ហើយសួរយ៉ាងម៉េច ហើយបានឯកសារម៉ោបញ្ជូនទៅខាងណា, មុនដំបូងធ្វើយ៉ាងម៉េច?

មៀនៈ មុនដំបូង យើងទៅយកអ្នកទោសម៉ោ យើងទៅដល់សរសេរឈ្មោះយើងអីចឹងទៅ ហើយយកឈ្មោះនេះមកយកទៅសួរចម្លើយ យកមកគេទៅយកអ្នកយកម៉ោយើងយកទៅ, យកទៅ ដល់បន្ទប់យើង ឲ្យអង្គុយស្រួលបួលទៅ ចាប់ផ្ដើមសរសេរ ចាប់ផ្ដើមសួរទៅ។

ដារ៉ាៈ ហើយសួរហើយកត់ជាក្រដាស?

មៀនៈ សួរហើយ យើងកត់តាមចម្លើយអីចឹងទៅ, ចម្លើយអ្នកទោសឆ្លើយ។

ដារ៉ាៈ កត់ហើយបញ្ជូនឯកសារទៅណា?

មៀនៈ បញ្ជូនទៅឲ្យអ្នកពិនិត្យឯកសារហ្នឹងហើយ, អ្នកពិនិត្យមានតែមេ មានតែតាចាន់, តាប៉ុនអ្នកពិនិត្យឯកសារ ហើយបន្ទាប់កទៅតាឌុច។ ពិនិត្យ២-៣ដំណាក់, ពិនិត្យមួយដំណាក់បានគេ បញ្ជូនបន្តទៅទៀត។

ដារ៉ាៈ បងមានដឹងទេថា ចម្លើយសារភាពហ្នឹងបញ្ជូនទៅដល់ដៃឌុចហើយ បញ្ជូនទៅណាទៀត?

មៀនៈ អត់ដឹង។

ដារ៉ាៈ មានដែលធ្លាក់ពីឌុចម៉ោវិញទេ?

មៀនៈ អាណឹងដូចខ្ញុំថាពីមុនអីចឹងថា ចម្លើយអត់ច្បាស់គឺមានបញ្ជូនមកវិញ។

ដារ៉ាៈ បញ្ជូនមកខាងអ្នកសួរវិញ?

មៀនៈ ហ្នឹងហើយ, ឲ្យសួរសារថ្មីបញ្ជាក់ម្ដងទៀត។

ដារ៉ាៈ បងមានដែលទទួលចម្លើយម៉ោវិញមានចំណាររបស់ឌុចទេ? មានចំណាររបស់ឌុចនៅលើចម្លើយសារភាព ហើយបញ្ជូនមកឲ្យបងសួរវិញ មានទេ?

មៀនៈ អត់ផង, គ្រាន់តែថា អានេះគេគ្រាន់ថា យើងបានដឹង យើងបានរៀនពីរបៀបរបបសួរចម្លើយវាអីចឹង តែខ្ញុំអត់បានទទួលមកវិញទេ។

ដារ៉ាៈ អីចឹងមុននឹងបងធ្វើជាអ្នកសួរចម្លើយ បងធ្លាប់រៀនសូត្រដែរ?

មៀនៈ រៀនហ្នឹង ដូចខ្ញុំថា ទៅអង្គុយមើលគេរៀន គេឲ្យយើងរៀនអង្គុយមើលគេ។ យើងយកអ្នកទោសម្នាក់ ទៅដល់ដាក់ឲ្យអង្គុយអីចឹងទៅ យើងទៅអង្គុយលើកៅអីមួយចាំមើលគេសួរទៅណា៎។

ដារ៉ាៈ ហើយមួយថ្ងៃសួរប៉ុន្មានដងទៅ?

មៀនៈ សួរ, ព្រលឹមឡើងម៉ោង៦ ទៅយកម្នាក់ម៉ោ យកមកឲ្យគេសួរ។ សួរយើងអង្គុយមើលដល់ម៉ោង១០ សម្រាកហើយណា៎។ សម្រាកយកអ្នកទោសទៅទុកនៅកន្លែងវិញ។ ដល់ពេលនេះ មកហូបបាយ។ ហូបបាយរួចសម្រាកដល់ម៉ោង២ បានទៅយកមកសួរទៀត។

សុជាៈ អីចឹងបង សំបុត្រដែលយើងទៅហៅអ្នកទោសយកមកសួរណឹង សំបុត្រហ្នឹងបងបានទទួលមកពីណាម៉ោ?

មៀនៈ សំបុត្រ, អាណឹងគេឧបមាថា កាលណឹងវាមានទូរស័ព្ទមួយម្នាក់, ឧបមាថា តាឌុចបញ្ជាឲ្យយើងសួរអ្នកណា, ឧបមាថា គាត់និយាយតាមទូរស័ព្ទម៉ោ ហើយយើងកត់ឈ្មោះទៅយកមក។

សុជាៈ ចុះអត់មានលិខិតផ្ទាល់ម៉ោពីឌុចអត់មានទេ?

មៀនៈ អត់ទេ។

សុជាៈ មានតែទូរស័ព្ទមកប្រាប់បង។

មៀនៈ ហ្នឹងហើយ។

ដារ៉ាៈ ទូរស័ព្ទម៉េច?

មៀនៈ អាតាឡូន់វិល...

ឧស្មានៈ ប្រើអាណឹង?

មៀនៈ ប្រើខ្សែ ទូរស័ព្ទខ្សែ។

ដារ៉ាៈ ទូរស័ព្ទមកថា ទៅយកអ្នកណាៗ ឌុចប្រាប់ម៉ោអីចឹងតែម្តង?

មៀនៈ ហ្នឹងហើយ ។

ដារ៉ាៈ ហើយយើងយកតាមហ្នឹងទៅ?

មៀនៈ យកទៅ ។

ដារ៉ាៈ ចុះម៉េច, ឧទាហរណ៍ បងទៅយកអ្នកទោសអីចឹង ដូចឌុចទូរស័ព្ទមកអីចឹង ទៅប្រាប់គេម៉េច ដឿ? បើយើងអត់មានស្នីបផ្ដាញអ្នកយាមគុកហ្នឹងណា៎?

មៀនៈ យើងជាអ្នកសួរចម្លើយ គេដឹងហើយ, ឲ្យតែយើងអ្នកសួរចម្លើយចូលទៅ គឺអ្នកយាមគុក ស្គាល់ទាំងអស់ ។ ទៅដល់យើងសរសេរឈ្មោះយើងបិុបដាក់ក្នុងបញ្ជីៗ ហើយឈ្មោះ នេះម៉ោយើង ស៊ីញ៉េខ្ទាច់ ។ យើងរបស់យើងនៅតាមនោះហើយ ។

ដារ៉ាៈ ហើយយកអ្នកទោសទៅសួរទៅ?

មៀនៈ យកអ្នកទោសសួរទៅ ។

ដារ៉ាៈ បងដែលជួបមុខឌុចញឹកញាប់ទេ?

មៀនៈ ជួបរាល់ថ្ងៃនៅក្នុងមន្ទីរហ្នឹង, ផ្ទះបាយជាមួយគ្នា ។

ដារ៉ាៈ ជំនិតរបស់ឌុចអ្នកណាខ្លះក្នុងហ្នឹង?

មៀនៈ កាលណឹងនិរសាគាត់មានតែ គឿង....

សុជាៈ អីចឹងបង ឌុច ការគ្រប់គ្រងរបស់ឌុចទៅលើកូនចៅ គាត់គ្រប់គ្រងបែបណាដែរបង?

មៀនៈ គ្រប់គ្រងផ្នែកនយោបាយ ឬផ្នែកអី?

សុជាៈ ដូចថា កាយវិការនៃការគ្រប់គ្រងរបស់គាត់ម៉ត់ចត់ ឬក៏យ៉ាងម៉េចអីយ៉ាងម៉េចដែរបង?

មៀនៈ ហ៊ឺ, ម៉ត់ចត់ណាស់ ។ គាត់ម៉ឺងមាត់ដាច់ខាតរបស់គាត់ ។

ដារ៉ាៈ កាលនៅគុកប៉េអែស(PS) មានអ្នកទោសច្រើនទេ?

មៀនៈ កាលណឹងវាតិចនៅឡើយទេ ។ វាបានច្រើនឡើងៗរកកន្លែងដាក់មិនបាន បានរើពីណុងមក ដាក់ទួលស្វាយព្រៃ ។

ដារ៉ាៈ នៅក្នុងមួយកំឡុងពេលនៅគុកទួលស្វាយព្រៃ មានអ្នកទោសប្រហែលប៉ុន្មានទៅបង?

មៀនៈ ច្រើនដែរ, គឺម៉ាសាលាទួលស្វាយព្រៃហ្នឹងវាមានសាលា៣ខ្នង ៣ជាន់ទៀត.....មានអ្នក ទោសនៅគេចាក់ផ្ទើបន្ទប់បិទស៊ីម៉ង់ប៊ិនៗណឹង, មួយបន្ទប់ម្នាក់ៗគ្រប់ ។ មានអាជាន់លើ

ខាងកើត ទួលស្វាយព្រៃសាលាខាងកើត មានអាបន្ទប់ទូលាយៗគេចាប់ដាក់ខ្ទេះគ្នា ច្រើនតែម្តងៗ ម៉ាបន្ទប់ គ្នាពេញមួយបន្ទប់ហ្នឹងតែម្តង...

សុជាៈ ហើយបងមានដែលឃើញអ្នកស្លាប់នៅក្នុងគុកហ្នឹងទេបង?

មៀនៈ អ្នកទោសមានដែរ មានស្លាប់ជម្ងឺរាគមួល..

សុជាៈ មានការស្លាប់ក្រៅពីជម្ងឺហ្នឹងទេបង?

មៀនៈ អត់!

សុជាៈ ចុះដូចជាការសម្លាប់ខ្លួនឯងរបស់អ្នកទោសមានទេបង?

មៀនៈ គ្រាន់តែបានឮ តែអត់បានឃើញៗ

ដារ៉ាៈ នៅក្នុងគុកមានប្រភេទអ្នកទោសអីខ្លះបង?

មៀនៈ អ្នកទោស, បើនិយាយពីកន្លែងគុក គឺមានតែអ្នកទោសក្បត់ជាតិអង្គការគេហ្នឹងតែម្តងៗ

ដារ៉ាៈ មានស្រីមានប្រុសមានអីដែរ?

មៀនៈ មាន!

ដារ៉ាៈ ក្មេងៗមានទេ?

មៀនៈ ក្មេងៗអត់មានទេ, មានតែស្រី នារី មានស្ត្រីអីចឹងៗ

ដារ៉ាៈ ចុះសួរចម្លើយទោសស្រី អ្នកណាអ្នកសួរទៅ?

មៀនៈ អ្នកសួរចម្លើយទូទៅ ជួនកាល ស្រេចតែគេឲ្យសួរពីនោះ សួរស្រីៗទៅ សួរប្រុសៗទៅៗ វាមិនរើសមុខទេៗ អត់មានថា អ្នកនេះសួរតែស្រី អត់ទេៗ

ដារ៉ាៈ ក្នុងកងសួរចម្លើយមានស្រីទេ? មានស្រីសួរចម្លើយ?

មៀនៈ អត់ទេ, អត់មានទេៗ

ឧស្មានៈ បងមានដែលបានឃើញអ្នកទោសមានផ្ទៃពោះ ឬមានកូននៅជាប់ខ្លួនទេ?

មៀនៈ មាន!

សុជាៈ បងមានចាំឈ្មោះទេ?

មៀនៈ អត់ចាំទេ យូហើយៗ

ដារ៉ាៈ ចុះកូនតូចៗយកទៅណាទៅ?

មៀនៈ កូនតូចនៅជាមួយម្តាយ ពេលគេយកទៅសួរចម្លើយ ទុកនៅនឹងគ្នាគាត់, មនុស្សស្រីច្រើន
តែដាក់នៅក្នុងបន្ទប់ធំ, អត់មានដាក់តែឯងទេ ។

ដារ៉ាៈ ហើយនៅក្នុងហ្នឹង បងមានដែលជួបអ្នកទោសបរទេសដែរ ដែលមានទេ?

មៀនៈ មានដែរ, មានយួន មានជនជាតិ មានជនជាតិភ្នែកខៀវ, មាន ។

សុជាៈ ជនជាតិប្រមុះស្រួច?

មៀនៈ ហ្នឹងហើយ ។

ដារ៉ាៈ មានច្រើនទេបង?

មៀនៈ ហេ, ខ្ញុំឃើញតែ ២-៣នាក់ ប្រហែលជា៣នាក់ ពួកស្បែកខៀវ ។

សុជាៈ បងពេលដែលបងបានឃើញពួកហ្នឹងហើយ ពេលណាដែលបងលែងបានឃើញពួកហ្នឹងត
ទៅទៀត?

មៀនៈ ខ្ញុំអ្នកនាំពួកហ្នឹងយកទៅឲ្យគេសួរចម្លើយ តែខ្ញុំអត់ចេះភាសាគេហ្នឹងយកទៅឲ្យគេសួរ
ចម្លើយ ។

សុជាៈ មានអ្នកចេះភាសាសួរចម្លើយណឹងដែរ?

មៀនៈ មាន!

សុជាៈ ពីណាគេបងមានចាំឈ្មោះទេ?

មៀនៈ អត់ចាំឈ្មោះទេ, ណឹងអ្នកសួរចម្លើយណឹងផ្សេង អ្នកបកប្រែណឹងផ្សេងទៀត អាអ្នកបកប្រែ
ហ្នឹង ។ មានអ្នកសួរផ្សេង, សួរហ្នឹងឈ្មោះ ប៉ុន អ្នកសួរ ។

សុជាៈ ចុះអ្នកបកប្រែ?

មៀនៈ អ្នកបកប្រែមិនដឹងឈ្មោះអីទេ, ពីដើមគេអ្នកទោសដែរ ។ ចេះភាសាអង់គ្លេសអីណឹង គេទុក
អ្នកទោសហ្នឹងយកទៅឲ្យបកប្រែ ។

សុជាៈ អីចឹង ឌុច គាត់អត់មានអីចុះម៉ោសួរខ្លួនឯងទេ?

មៀនៈ អត់ទេ, អត់ដែលម៉ោសួរទេ ។ គាត់អ្នកគ្រប់គ្រងក្នុងមន្ទីរហ្នឹង គាត់អ្នកពិនិត្យឯកសារ
បញ្ជារលើគាត់ហ្នឹងតែម្តង ។ គាមសួរចម្លើយសួរអីអត់ដែលឃើញចុះម៉ោទេ ។

សុជាៈ ហើយការគ្រប់គ្រងរបស់គាត់មានភាពយ៉ាងម៉េចដែរ, ការគ្រប់គ្រងរបស់ ឌុច?

មៀនៈ ហេ, សភាពរបស់គាត់គឺម៉ឺងមាត់ ។

ដារ៉ាៈ បងស្គាល់ហ៊ុយទេ?

មៀនៈ ហ៊ុយ, ស្គាល់ៗ ហ៊ុយគាត់សមាជិក គាត់ទទួលម៉ាផ្នែកធ្វើស្រែនៅព្រៃសរឯណោះ ។ គាត់សមាជិកក្នុងមន្ទីរហ្នឹងដែរ ។

ដារ៉ាៈ ហ៊ុយ មានប៉ុន្មាននាក់នៅទួលស្លែង?

មៀនៈ ហ៊ុយ មានតែម្នាក់ហ្នឹង ។

ដារ៉ាៈ ចុះមានឃើញហ៊ុយ ស្រែ ហ៊ុយអីនោះបង?

មៀនៈ ហ៊ុយ សមាជិក គាត់អ្នកគ្រប់គ្រងធ្វើស្រែហ្នឹងហើយ, ខាងផលត់ដំ ។

ដារ៉ាៈ ហ៊ុយ ខាងកងការពារបងមានស្គាល់?

មៀនៈ ហ៊ុយ ការពារ! ហេ, ដូចភ្លេចអស់ហើយ, ចាំមិនច្បាស់ទេអ្នកតូចៗដូចគ្នាវាភ្លេចអស់ហើយ ។ បើអ្នកធំ អាណឹងមេៗនៅចាំតែម្តង ។

ដារ៉ាៈ ចុះបងរៀបរាប់មើល អ្នកណាធំជាង ហើយបន្ទាប់ៗមកទៀតនៅទួលស្លែង?

មៀនៈ ធំជាងគេ គឺ តាឌុចហ្នឹងហើយ, បន្ទាប់មក តាហ៊ិ, បន្ទាប់មក តាហ៊ុយហ្នឹងហើយ តែតាហ៊ុយគាត់អត់មាននៅផ្នែកខាងក្នុងនេះ គាត់នៅខាងក្រៅ ។ បើនៅខាងក្នុងបន្ទាប់ពី តាហ៊ិមក ចាន់, ចាន់ម៉ៅ ប៉ុន, អាណឹងផ្នែកខាង(នៅទួលស្លែង) ។ ហើយធំបន្ទាប់ទៀត ដូ, ផល, ប៉ូច អ្នកការពារ ប្រធានកងការពារ, ប្រធានកង ព្រេច នេះ ។

ដារ៉ាៈ បង, អ្នកទោសដល់ពេលសួរចម្លើយចប់សព្វគ្រប់ ហើយគេច្រើនបញ្ជូនទៅខាងណា?

មៀនៈ អត់ដឹង, យើងអ្នកសួរដឹងតែសួរ អ្នកយាមដឹងតែយាម ។ គេយកត្រូវការដាក់ឡានគេដាក់ឡានឃ្លុបទៅបាត់អីចឹងទៅ តែមិនដឹងទៅណាទេ ខ្ញុំអត់ដឹងដែរ ។

ដារ៉ាៈ ភាគច្រើនឡានឃ្លុបមកយកអ្នកទោសម៉ោងប៉ុន្មាន?

មៀនៈ យកអត់រើសម៉ោងទេ, ជួនកាលព្រឹក ជួនកាលថ្ងៃត្រង់ ជួនកាលយប់ក៏មកដែរ អត់មានរើសពេលផង ។ ឡានឃ្លុបអាកាត់កាត់ចិន ដាក់ឃ្លុបជិតឈឹង ។

សុជាៈ ចុះបង, អ្នកទោសបរទេសហ្នឹងត្រូវគេបញ្ជូនចេញដែរ ឬនៅក្នុងហ្នឹង?

មៀនៈ ហេ, កាលណុងខ្ញុំអត់ដឹងដែរ អត់ដឹងគេបញ្ជូនចេញដែរ ព្រោះកន្លែងវា ខ្ញុំយកទៅឲ្យគេសួរបានតែ៣-៤ថ្ងៃ ខ្ញុំត្រូវបែកពីគេ ។

សុជាៈ បងអត់បានដឹងដំណឹងពីអ្នកទោសបរទេសហ្នឹងទៀតទេ?

មៀនៈ  អត់ដឹងទេ ។

ដារ៉ាៈ  កាលដែលសួរចម្លើយ  សួរដើម្បីអីគេបង?

មៀនៈ  សួរដើម្បីរក  គេថាមានអ្នកក្បត់ជាតិ, គេសួររកខ្សែរយៈអ្នកក្បត់ជាតិគេនោះ ។

ដារ៉ាៈ  ហើយចម្លើយសារភាពដែលឆ្លើយម៉ោ  បានដោយឆ្លើយធម្មតា  ឬក៏មានទារុណកម្មអី?

មៀនៈ  មានទារុណកម្មខ្លះដែរ  ខ្លះឆ្លើយតាមធម្មតា ។

ដារ៉ាៈ  បានចម្លើយម៉ោផ្ញើទៅខាងលើ?

មៀនៈ  ផ្ញើទៅលើតាមខ្សែរយៈ ។

ដារ៉ាៈ  ហើយមានដែលឃើញអ្នកធំណាផ្សេងទៀតមកមើលទួលស្លែងទេ?

មៀនៈ  មានតែ  តាសុន  សេន ។  សុន  សេន  ម៉ាខែ  ឬ៣ខែ  គាត់ម៉ោបង្រៀនម្តង, បង្រៀនពីផ្នែកនយោបាយ ។

ដារ៉ាៈ  បង្រៀនអ្នកធ្វើការនៅហ្នឹងទាំងអស់ឬ?

មៀនៈ  ទៅទាំងអស់ ។

ដារ៉ាៈ  ឌុច  អីចូលរួមទេ?

មៀនៈ  ចូល, ចូលរួមទាំងអស់ ។

សុជាៈ  បងមានចាំសម្តីដែលគាត់បង្រៀនមានស្អីខ្លះបង?  ខ្លឹមសារនៃការបង្រៀន?

មៀនៈ  ហ៊ឺ, អត់ចាំ ។  វាមិនសូវចាំ  ឥឡូវដូចជាភ្លេចភ្លាំងៗអស់ហើយរាល់ថ្ងៃ  គ្រាន់ធ្វើការខ្លួនឯងក៏ភ្លេចដែរ  មិនដូចពីដើមទេ ។

សុជាៈ  អ្នកទោសត្រូវបានគេដាក់ដោយឡែកពីអ្នកទោសខ្មែរយើង  ឬក៏ដាក់ជាមួយគ្នា?

មៀនៈ  ដាក់បន្ទប់ដោយឡែក ។

សុជាៈ  ការឲ្យម្ហូបអាហារទៅអ្នកទោសបរទេស  ឲ្យទៅដូចនឹងអ្នកទោសខ្មែរ  ឬអត់?

មៀនៈ  ឲ្យដូចតែគ្នា  ចំណីដូចតែគ្នា ។

ខស្មានៈ  ពេលដែលអ្នកទោសមិនព្រមឆ្លើយ  ដូចថាសួរថា  តើខុសអីបានអង្គការចាប់ម៉ោ,  បងមានប្រើសំណួរណឹងទេ?

មៀនៈ  ប្រើ ។

ខស្មានៈ  ចុះបើអ្នកទោសហ្នឹងនៅតែមិនឆ្លើយ  តើធ្វើយ៉ាងម៉េច?

មៀនៈ ប្រើទារុណកម្ម ។ ទារុណកម្មមានវ៉ៃ មានឆក់អីចឹងទៅ ។

ខស្នានៈ ហើយចុះក្រោយពីព្រើទារុណកម្មហើយ អ្នកទោសឆ្លើយទាំងអស់?

មៀនៈ ខ្លះឆ្លើយ ខ្លះអត់អីចឹងដែរ អត់រហូតក៏មានដែរ ។

ខស្នានៈ ចុះបើអត់រហូត..

មៀនៈ អត់រហូត, យើងសួរអត់ឆ្លើយ យើងសួរម្នាក់ យើងសួរខ្លួនឯងអត់ចេញ យើងប្រគល់ឲ្យអ្នកនោះសួរម្ដងទៅ, យកទៅទុកម៉ាខែ កន្លះខែអីចឹងទៅ គេចាត់តាំងឲ្យអ្នកផ្សេងមួយទៀត យក ម៉ោសួរផ្សេងទៀតទៅ ។

ខស្នានៈ ចុះដល់លទ្ធផលចុងក្រោយមានអត់ឆ្លើយអីចឹងរហូត ឬយ៉ាងម៉េច?

មៀនៈ ហេ, មិនដឹងអីដែរ បែបមានអត់ដែរណឹង មានឆ្លើយដឹង ខ្ញុំអត់សូវដឹងអស់ដែរ ។

ខស្នានៈ អ្នកទោសជាមធ្យមរយៈពេលមិនយូរមិនឆាប់ទេ ដែលត្រូវបានឃុំនៅកន្លែងហ្នឹង រយៈពេលប៉ុន្មាន? ដូចថាមិនយូរពេក មិនឆាប់ពេក?

មៀនៈ អាណឹងតាមឈ្មោះគេឲ្យពូលើម៉ោ ឧបមាថាឈ្មោះគេឲ្យពីលើម៉ោ គ្រាន់តែម៉ោដល់យកទៅសួរចម្លើយភ្លាមក៏មាន, ជួនកាលគេប្រញាប់ ។ ជួនកាលគេយកម៉ោទុកហ្នឹង២-៣ខែអត់ទាន់ម៉ោសួរ ចម្លើយក៏មានដែរ ។ អាណឹងកាលពីខ្ញុំនៅយាមនៅឡើយណា៎ ។

ខស្នានៈ ហើយពេលគេយកចេញពីគុកហ្នឹង គេយកទៅណាបងមានដឹងទេ?

មៀនៈ មិនដឹងគេយកទៅណា ដូចខ្ញុំថាអីចឹង, គេដាក់ឡានឃ្លុប់ទៅបាត់ទៅ មិនដឹងទៅណា ។

ដារ៉ាៈ ហើយដែលឃើញត្រឡប់មកវិញទេ?

មៀនៈ អត់ទេ, តែយកទៅចេញពីណឹង គឺអត់មានត្រឡប់មកវិញទេ ។

ខស្នានៈ មានដែលដោះលែងអ្នកទោស?

មៀនៈ ហេ, ដោះលែងដូច...មានតែដោះលែងឲ្យធ្វើការនៅក្នុងនោះ ថាដោះលែងឲ្យចេញទៅក្រៅអត់ដឹងដែរ ។

ខស្នានៈ ចុះអ្នកដោះលែងឲ្យធ្វើការនៅក្នុងណុង បងចាំខ្លះទេ?

មៀនៈ ឲ្យមានធ្វើគុ ធ្វើទូរ ធ្វើសេដ្ឋកិច្ចដាំបាយដាំអីឲ្យអ្នកទោសគ្នាឯង ។

ខស្នានៈ បងមានចាំឈ្មោះខ្លះ?

មៀនៈ ចាំឈ្មោះ ប៉ាវ ។

ខស្មានៈ សព្វថ្ងៃនៅឯណា?

មៀនៈ អត់ដឹងនៅឯណា ។

ខស្មានៈ ចាំអ្នកណាម្នាក់ទៀត?

មៀនៈ ចាំម្នាក់ទៀតស្រី យាយម៉ែន, យាយម៉ែននៅកំពង់ឆ្នាំង ។

ខស្មានៈ សព្វថ្ងៃនៅទេ យាយម៉ែន?

មៀនៈ មិនដឹងនៅឯណា, សព្វថ្ងៃបាត់ឈ្មោះដូចអត់ឮឈ្មោះ ។

ខស្មានៈ មានចាំទៀតទេ?

មៀនៈ អត់ទេ ចាំបានតែ២នាក់ ។

សុជាៈ បង ហេតុអីបានជាអ្នកទោសត្រូវដោះលែងឲ្យធ្វើតុ ទូរ ខុសប្លែកគ្នាយ៉ាងម៉េច?

មៀនៈ អត់ដឹងដែរ ។ អាណឹងស្រេចតែគេ គេបញ្ជាពីណុងម៉ោ ។ ឧបមាថា គេខ្វះអីចឹងគេរើស យកដាក់ទៅ, ស្រេចចិត្តគេ ។

ខស្មានៈ បងស្គាល់អ្នកធ្វើការនៅក្នុងណុងជាជនជាតិចាម ដែលស្គាល់ទេ?

មៀនៈ ដូចអត់មានបានចូលធ្វើនៅណឹងទេ ។ ខ្ញុំនឹកមិនឃើញសោះចាម ។

ខស្មានៈ អ្នកសួរនៅកងជាមួយបង បងមានដែលស្គាល់អ្នកសួរណាឈ្មោះប្រាក់ខនៈ?

មៀនៈ ..........(មៀនរកនឹកឡើងវិញ) ..... ។

ខស្មានៈ អរគុណបងច្រើនដែលបងជួយរៀបរាប់ប្រាប់រឿងរ៉ាវខ្ញុំទាំងអស់ បើមានពេលយ៉ាងម៉េច ខ្ញុំមកលេងជាមួយបងទៀត ។

ដារ៉ាៈ រាល់ថ្ងៃបងមានដឹងថា គេបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

មៀនៈ ដឹង ។

ដារ៉ាៈ ហើយបងយល់យ៉ាងម៉េចដែរ?

មៀនៈ ខ្ញុំអត់សូវយល់ដែរ ។

ដារ៉ាៈ បងមានអារម្មណ៍ភិតភ័យទេ នៅពេលដែលមានឮថា...

មៀនៈ ខ្ញុំអត់មានភិតភ័យអីទេ ព្រោះការយើងរស់នៅក្រោមបង្គាប់គេ ។ ការចាត់តាំងរបស់គេ គេឲ្យធ្វើអីយើងធ្វើណឹងតាមតែគេ បើយើងមិនធ្វើគឺស្លាប់ខ្លួនឯង ដូចខ្ញុំនៅក្នុងគុកណឹង គ្នាឯងមាន ងាប់ច្រើនដែរ វាមានជាប់គុកគ្នាឯង អាជាប់គុកក៏មានដែរ ។ អាសួរ

ចម្លើយក៏មានជាប់គុក អាអ្នកយាមអ្នកទោសក៏មានជាប់គុក អាអ្នកប្រធានក៏មានជាប់គុក ដូចឈ្មោះ ដូ ឈ្មោះ ប៉ូច ជាប់គុក ខ្លួនឯង ណឹងប្រធានគេផង ។

សុជាៈ បងចង់ឲ្យមានតុលាការណឹងកើតឡើង?

មៀនៈ ហេ, អាណឹងការចង់ ក៏ដូចជាមិនចង់ ។ អាណឹងវាតាមច្បាប់អន្តរជាតិគេធ្វើចុះ ។

ដារ៉ាៈ អីចេះ ដែលខ្ញុំសួរវាអីចេះ ព្រោះរាល់ថ្ងៃនេះឌុចកំពុងនៅក្នុងគុក ហើយនៅថ្ងៃមុខច្បាស់នឹងកាត់ទោសឌុចហើយមិនអីចឹង, ហើយបើសិនជាឧទាហរណ៍ថា កាត់ទោសទៅគេចង់បានបងឲ្យទៅ ជួយឆ្លើយបំភ្លឺនៅចំពោះតុលាការទាក់ទងរឿងឌុច បងហ៊ានទៅទេ?

មៀនៈ អាណឹងបើការគេហៅទៅ ខ្ញុំក៏ទៅដែរ ។

ដារ៉ាៈ បងអត់ខ្លាចទេ?

មៀនៈ អត់ខ្លាចទេ ។

ខស្មានៈ ដែលនិយាយរឿងប្រាប់ពីណាទេបង ថាបងជាអ្នកយាម ជាអ្នកសួរចម្លើយនៅកន្លែងទួលស្លែង បងមានដែលនិយាយប្រាប់អ្នកភូមិ អ្នកស្រុក?

មៀនៈ ខ្ញុំដើរនិយាយប្រាប់ពេញណឹង ខ្ញុំមានខ្លាចអីខ្ញុំ........

ដារ៉ាៈ អរគុណបងច្រើនណាស់ ។